អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) បានចេញសេចក្តីសម្រេចរបស់ខ្លួន បដិសេធបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ) ដែលបានស្នើសុំឲ្យ អ.ជ.ត.ក បញ្ជូនរឿងក្តីប្រឆាំងនឹង យឹម ទិត្យ ទៅកាន់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ដើម្បីធ្វើការជំនុំជម្រះ។ បណ្តឹងសាទុក្ខនោះផ្អែកលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែលរួមមាន "យន្តការស្វ័យប្រវត្តិ" ដែលតម្រូវឲ្យរឿងក្តីបន្តដំណើរការទៅជំនុំជម្រះ ប្រសិនបើមិនមានចៅក្រមយ៉ាងហោចណាស់ចំនួនបួនរូប ក្នុងចំណោមចៅក្រមទាំងប្រាំរូបនៃអង្គបុរេជំនុំជម្រះ (អ.ប.ជ) បដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះទេនោះ ដែលចៅក្រម អ.ប.ជ មិនបានធ្វើដូច្នោះឡើយ នៅក្នុងសេចក្តីសម្រេចខែកញ្ញា ឆ្នាំ២០២១ របស់ខ្លួន។

ចៅក្រមនៃ អ.ជ.ត.ក ទាំងអស់បានឯកភាពថា វាស្ថិតនៅក្នុងផលប្រយោជន៍យុត្តិធម៌ក្នុងការស្តាប់សំណើរបស់ ស.ព.អ។ ដោយមានមតិជំទាស់មួយ អ.ជ.ត.ក បានសន្និដ្ឋានថា អវត្តមានដីកាបញ្ជូនរឿងទៅជំនុំជម្រះជាក់លាក់ និងអាចអនុវត្តបានក្រោយពីសេចក្តីសម្រេចរបស់ អ.ប.ជ បានផ្តល់យុត្តិកម្មដល់ការបញ្ចប់រឿងក្តីមុនពេលការសម្រេចណាមួយអាចធ្វើឡើងទាក់ទងនឹងពិរុទ្ធភាពរបស់ យឹម ទិត្យ។ សេចក្តីសម្រេចរបស់ អ.ជ.ត.ក ជាសេចក្តីសម្រេចស្ថាពរ និងមិនត្រូវប្តឹងសាទុក្ខឡើយ។

នៅក្នុងមតិជំទាស់របស់គាត់ ចៅក្រម Maureen Harding Clark បានឯកភាពថា រឿងក្តីរបស់ យឹម ទិត្យ គួរត្រូវបញ្ចប់ ប៉ុន្តែដោយផ្អែកលើសំអាងហេតុហួសពីអវត្តមាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព។ ដោយទទួលស្គាល់អំណះអំណាងជាធម្មានុរូបរបស់ ស.ព.អ គាត់បានសន្និដ្ឋានថា ផ្អែកតាមគោលការណ៍ស្តីពីយុត្តិធម៌ សេចក្តីសម្រេចរបស់ចៅក្រម អ.ប.ជ គប្បីត្រូវបានបដិសេធចោលដោយសារកង្វះភាពប្រាកដប្រជា និងសច្ចភាពផ្នែកច្បាប់របស់វា និងការបរាជ័យរបស់វាក្នុងអនុញ្ញាតឲ្យយន្តការស្វ័យប្រវត្តិអាចប្រតិបត្តិការបាន។ ទោះជាយ៉ាងណា គាត់បានសន្និដ្ឋានថា ដោយផ្អែកលើភាពមិនចុះសម្រុងគ្នាដែលមិនអាចសម្របសម្រួលបាន រវាងភាគីជាតិ និងអន្តរជាតិនៃ អ.វ.ត.ក វាមិនមានប្រយោជន៍អ្វីសម្រាប់ អ.ជ.ត.ក ក្នុងការបង្គាប់ឲ្យ អ.ប.ជ ពិចារណាលើការខ្វែងយោបល់គ្នារវាងសហចៅ

ក្រុមស៊ើបអង្កេត លើបញ្ហាថាតើ យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ឬយ៉ាងណានោះឡើយ។ ហេតុដូច្នេះ មិនមានមធ្យោបាយច្បាស់លាស់ ដើម្បីធ្វើការកែតម្រូវសេចក្តីសម្រេចមានវិការៈរបស់ អ.ប.ជ ឡើយ និងផ្អែកលើមូលហេតុចុងក្រោយនេះ គាត់សម្រេចថា រឿងក្តីគួរត្រូវបានបញ្ចប់។

វាមានសារសំខាន់សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង យឹម ទិត្យ និងសង្គមកម្ពុជាជាទូទៅ ក្នុងការយល់អំពីអត្ថន័យនៃសេចក្តីសម្រេចលើកលែងចោទប្រកាន់របស់ អ.ជ.ត.ក ថាតើវាមានន័យបែបណានោះ។ អ.ជ.ត.ក មិនបានសន្និដ្ឋានថា យឹម ទិត្យ គ្មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មដ៏មហាធ្ងន់ធ្ងរ ដែលរូបគាត់ត្រូវបានចោទប្រកាន់នោះទេ រួមទាំងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាអំពើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ អ.ជ.ត.ក មិនបានធ្វើការសន្និដ្ឋានណាមួយលើពិរុទ្ធភាព ឬភាពគ្មានទោសរបស់ យឹម ទិត្យ នោះទេ។ ផ្ទុយទៅវិញ សេចក្តីសម្រេចលើកលែងចោទប្រកាន់នេះមានន័យថា មិនមានការជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក ដើម្បីធ្វើការសម្រេចតាមផ្លូវតុលាការលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ឡើយ។

ដូច្នេះ ជាថ្មីម្តងទៀត ការទទួលខុសត្រូវស្ថិតនៅលើតុលាការជាតិកម្ពុជា ក្នុងការផ្តល់យុត្តិធម៌ តាមរយៈការកំណត់ថាតើ យឹម ទិត្យ ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដ៏មហាធ្ងន់ធ្ងរ នៅក្នុងការជំនុំជម្រះមួយដែលឯករាជ្យ ឥតលម្អៀង ដែលធ្វើការសម្រេចផ្អែកតែទៅលើច្បាប់ និងអង្គហេតុប៉ុណ្ណោះ និងការធានាឲ្យមានភាពត្រឹមត្រូវយុត្តិធម៌សម្រាប់គ្រប់ភាគីទាំងអស់ រួមទាំងភាគីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីផង៕